ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាយមានជ័យ
រដ្ឋបាលក្រុងប៉ោយប៉ែត
លេខ: ០០៤/២១ សណន

ថ្ងៃសុក្រ ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤
ប៉ោយប៉ែត ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២១

# សេចក្តីណែនាំ
## ស្តីពី
## ការផ្អាកការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រក្រុងប៉ោយប៉ែត

យោង៖ - ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ០០៤/២១ សណន ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

រដ្ឋបាលក្រុងប៉ោយប៉ែត សូមជម្រាបជូនដល់ម្ចាស់អាជីវករដែលលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទទាំងលក់ដុំ និងលក់រាយ និងម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន ក្លឹបអាហារ ហាងកេសជ្ជៈគ្រប់ប្រភេទ ជ្រាបថា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការកាត់ផ្តាច់នូវការចម្លងក្នុងសហគមន៍ នៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលក្រុង សូមធ្វើការផ្អាកជាបណ្តោះអាសន្ននូវការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទទូទាំងក្រុងប៉ោយប៉ែត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់មានការជូនដំណឹងជាថ្មី។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលាក្រុង អធិការនគរបាលក្រុង មេបញ្ជាការកងរាជអាវុធហត្ថក្រុង អភិបាលនៃគណៈអភិបាលក្រុង ការិយាល័យ-អង្គភាព ស៊ីវិលឯកជន និងម្ចាស់អាជីវករដែលលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទទាំងលក់ដុំ និងលក់រាយ និងម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន ក្លឹបអាហារ ហាងកេសជ្ជៈគ្រប់ប្រភេទ ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

អភិបាលក្រុង

គាត ហ៊ុល

**ចម្លងជូន**
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ក្រុមប្រឹក្សាក្រុងប៉ោយប៉ែត
"ដើម្បីគោរពជូនជ្រាប"
- អធិការដ្ឋាននគរបាលក្រុង
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុង
- បញ្ជាការដ្ឋានទ័ពក្រសិណក្រុង
- រដ្ឋបាលសង្កាត់ទាំងបី
"ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ